# ឧបករណ៍ Microsimulation - ប្រព័ន្ធគាំពារសង្គម ប្រកបដោយបរិយាបន្នពិការភាព

## សេចក្តីផ្តើម



ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ ទោះបើស្ថិតក្នុងស្ថានភាពវិបត្តិកូវីដ-១៩ ក៏ដោយ។ នៅឆ្នាំ ២០១៥ ប្រទេសកម្ពុជាបានឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយមានគោលបំណងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។

នៅពេលដែលប្រទេសឆ្ពោះទៅរកគោលដៅនេះ វាជារឿងសំខាន់ដែលជនមានពិការភាពមិនត្រូវបានទុកចោល ហើយអាចទទួលបានអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ចនេះ។

គម្រោងកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាពគឺជាមធ្យោបាយដ៏សំខាន់មួយដែលលើកកម្ពស់និងអនុញ្ញាតឱ្យមានការចូលរួម និងការទទួលបានអត្ថប្រយោជន៍ប្រកបដោយសមធម៌ និងយុត្តិធម៌សម្រាប់ជនមានពិការភាព។ ការកសាងប្រព័ន្ធគាំពារសង្គមបែបទំនើបសម្រាប់ជនមានពិការភាពនៅកម្ពុជាអោយស្របតាមសិទ្ធិរបស់ប្រជាពលរដ្ឋដែលបានចែងរដ្ឋធម្មនុញ្ញ ដើម្បីទទួលបានរបបសន្តិសុខសង្គម ហើយមានសារៈសំខាន់ជាពិសេសនៅពេលដែលប្រទេសចាប់ផ្តើមស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិកូវីដ-១៩។

## ទិដ្ឋភាពទូទៅ

**ឧបករណ៍ Microsimulation ត្រូវបានផ្តួចផ្តើមដោយកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌** ហើយវាត្រូវបានបង្កើតឡើងដោយអង្គការ Development Pathways ដោយប្រើ ភាសាកម្មវិធីកុំព្យូទ័រ opensource ហៅថា R និង Rshiny ដែលជាកម្មវិធី គេហទំព័រឥតគិតថ្លៃ និងកញ្ចប់អភិវឌ្ឍន៍ផ្ទាំងគ្រប់គ្រង។

**ឧបករណ៍នេះអនុញ្ញាតឱ្យអ្នកគាំទ្រ និងអ្នកអនុវត្តកម្មវិធីកិច្ចគាំពារសង្គម** អាចស្វែងយល់ និងមើលឃើញ ពីផលជះ និងសក្តានុពលនៃប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាពនៅកម្ពុជា។

**គោលបំណងនៃឧបករណ៍នេះគឺដើម្បីបង្កើនការពិភាក្សា**ជុំវិញការកសាងប្រព័ន្ធសន្តិសុខសង្គមបែបទំនើបនៅកម្ពុជា។ លទ្ធផលដែលបានពីឧបករណ៍នេះគឺសម្រាប់ជាឧទាហរណ៍ប៉ុណ្ណោះ ហើយមិនគួរត្រូវបានយក ជាការព្យាករណ៍ពិតប្រាកដនៃការផ្លាស់ប្តូរសុខុមាលភាពណាមួយនោះទេ។

**ឧបករណ៍ Microsimulation ត្រូវបានរៀបចំឡើង** ដើម្បីធ្វើជាគំរូនិងផ្តល់នូវការប៉ាន់ប្រមាណលើការ គ្របដណ្តប់ភាពគ្រប់គ្រាន់ និងផលជះនៃគម្រោងកម្មវិធីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាពនៅកម្ពុជា។
**ឧបករណ៍នេះផ្តល់នូវគំរូចំណាយ** ដើម្បីប៉ាន់ប្រមាណកម្រិតនៃការវិនិយោគដែលនឹងត្រូវបានទាមទារ សម្រាប់កម្មវិធីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាពដែលបានស្នើឡើង។
**ឧបករណ៍ Microsimulation s គឺផ្អែកលើទិន្នន័យចុងក្រោយបង្អស់របស់ CSES ឆ្នាំ ២០១៩ និង ២០២០** ដែលបានកំណត់អត្តសញ្ញាណជនមានពិការភាពដោយការសួរសំណួរផ្អែកលើមុខងាររាងកាយ ដែលស្រដៀងនឹងកម្រងសំណួររបស់Washington Group ។ ឧបករណ៍នេះក៏ប្រើទិន្នន័យខ្នាតតូចផ្នែក សេដ្ឋកិច្ច និងប្រជាជនសាស្ត្រពី IMF និង UN DESA ដើម្បីបង្កើតការប៉ាន់ប្រមាណតម្លៃ។

## ការពិពណ៌នាអំពីឧបករណ៍ - មាតិកានិងមុខងារ

**ឧបករណ៍នេះផ្តល់ជាជម្រើសលើប្រព័ន្ធកិច្ចគាំពារសង្គមដែលមានបរិយាបន្នពិការភាពទូលំទូលាយសម្រាប់ប្រទេសកម្ពុជា។**
**ឧបករណ៍នេះមានកម្មវិធីចំនួនបីសំខាន់ៗរួមមាន៖ ១. អត្ថប្រយោជន៍សម្រាប់កុមារមានពិការភាព; ២. អត្ថប្រយោជន៍សម្រាប់មនុស្សពេញវ័យមានពិការភាព; ៣. អត្ថប្រយោជន៍នៃជនចាស់ជរា។**
**ឧបករណ៍នេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់ស្នើការជំឡើងកម្មវិធីទាំងនេះ**ដោយជ្រើសរើសសំណុំប៉ារ៉ាម៉ែត្រកម្មវិធីចំនួនបីរួមមាន៖ តម្លៃផ្ទេរ កម្រិតគ្របដណ្តប់ និងការចំណាយរដ្ឋបាល។
**នៅពេលដែលប៉ារ៉ាម៉ែត្រកម្មវិធីត្រូវបានបញ្ចូល អ្នកប្រើប្រាស់អាចវិភាគឃើញអំពី៖**

- **កម្រិតនៃការវិនិយោគ** ដែលត្រូវការដើម្បីអនុវត្តកម្មវិធី
- **ប្រសិទ្ធភាពនៃកម្មវិធី** ក្នុងការឈានដល់ក្រុមផ្សេងគ្នានៃចំនួនប្រជាជនទូទាំងប្រទេស
- **ផលជះនៃកម្មវិធី** អាចមានលើអំណាចទិញ ភាពក្រីក្រ និងវិសមភាព

**លទ្ធផលពីឧបករណ៍មិនឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់កម្មវិធី ACCESS** ទេ កំហុសទាំងឡាយនៅក្នុងឧបករណ៍ជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ។
**ឧបករណ៍នេះត្រូវបានរចនាឡើងដើម្បីធ្វើឱ្យងាយស្រួល**ប្រើ ហើយអ្នកប្រើប្រាស់ត្រូវការជំនាញកុំព្យូទ័រ និងអ៊ីនធឺណិតជាមូលដ្ឋានដើម្បីអាចប្រើប្រាស់ឧបករណ៍នេះបាន។
**មគ្គុទ្ទេសក៍ណែនាំជាជំហាន ៗ សម្រាប់ការប្រើប្រាស់ឧបករណ៍ត្រូវបានផ្តល់ជូន។** មគ្គុទ្ទេសក៍នេះក៏បង្ហាញពីវិធីសាស្ត្រ ក៏ដូចជាទិន្នន័យសំខាន់ៗ និងការសន្មត់ដែលបានប្រើ។ ជាចុងក្រោយនៅចុងបញ្ចប់នៃការណែនាំនេះ សទ្ទានុក្រមនៃពាក្យគន្លឹះត្រូវបានបង្ហាញ។
**អ្នកប្រើត្រូវបានលើកទឹកចិត្តឱ្យចូលប្រើឧបករណ៍ Microsimulation និងមគ្គុទ្ទេសក៍អ្នកប្រើ តាមរយៈ**

➔ **តំណនេះ** https://devpathways .shinyapps.io/access_disability_sptool/

➔ **តាមខ្យូអរកូត**